01072973

002/19-09-2007-ECCC/TC
E1/255

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 03 / 2015
ម៉ោង (Time/Heure): 14:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ចន្ទ ទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥

**សវនាការលើភស្តុតាង - ថ្ងៃ ២៣៦**

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Maddalena GHEZZI**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ង, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK, លោក Travis FARR |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សួន វិសាល |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី |

| |
|---|
| សាក្សី/ដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ជាំង ស្រីមុំ (2-TCW-834), លោក កែវ ច័ន្ទដារា (2-TCW-964) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី ស្វ សុទ្ធារី |
| ផ្សេងៗ៖ កញ្ញា ស្រី ណាក់, កញ្ញា សុក សុភ័គមណីកា, កញ្ញា ណី សុមេត្តា, លោក ឈុន ម៉ារ៉ូហ្សា, កញ្ញា តូច គន់នារី, លោក Mario D'ALESSANDRO |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៧ |
| ការស្នើសុំលះបង់សិទ្ធិរបស់ នួន ជា ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការ | អង្គជំនុំជម្រះ<br>(មេធាវីការពារក្ដី នួន ជា) | ០៩.០៨ | ០៩.១២ |
| ការតាំងសំណួរទៅសាក្សី ជាំង ស្រីមុំ (2-TCW-834) | មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៣<br>០៩.៣៥ | ០៩.៣០<br>១០.១១ |
| ការតាំងសំណួរទៅកាន់សាក្សី កែវ ច័ន្ទដារា (2-TCW-964) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ១០.៣៦<br>១០.៤៤<br>១៤.១៧<br>១៤.២៦<br>១៥.៥៥ | ១០.៤៤<br>១៤.១៦<br>១៤.២៦<br>១៥.៥៥<br>១៦.០៧ |
| សេចក្ដីសម្រេចផ្ទាល់មាត់ | អង្គជំនុំជម្រះ | ១៥.០៣ | ១៥.០៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីបានរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន លើកលែងតែ លោក Arthur VERCKEN មេធាវីអន្តរជាតិការពារក្តីឱ្យលោក ខៀវ សំផន អវត្តមានដោយសារមូលហេតុសុខភាព និង ជនជាប់ចោទ នួន ជា មានវត្តមានពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>ការស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការរបស់ នួន ជា</u>**

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីពីសំណើសុំរបស់នួនជា ក្នុងការតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ អង្គ-ជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា អនុលោមតាមវិធាន ៨១.៥ នៃវិធានផ្ទៃក្នុង។

**<u>ការតាំងសំណួរទៅសាក្សី ជាំង ស្រីមុំ (2-TCW-834)</u>**

មេធាវីការពារក្តី នួន ជា បានចាប់ផ្តើមតាំងសំណួរទៅសាក្សី ជាំង ស្រីមុំ។ បន្ទាប់មកក្រុមមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរបន្ត។

**<u>ការតាំងសំណួរទៅសាក្សី កែវ ច័ន្ទដារា (2-TCW-964)</u>**

អង្គជំនុំជម្រះបានសួរសំណួរមួយចំនួនទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សី កែវ ច័ន្ទដារា (2-TCW-964) ព្រមទាំងបានប្រាប់អំពីសិទ្ធិ និងកាតព្វកិច្ចដល់សាក្សី។ បន្ទាប់មក សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានតាំងសំណួរទៅសាក្សី។

**<u>ការចេញសេចក្តីសម្រេចផ្ទាល់មាត់</u>**

អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ដែលស្នើឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញ អំពីការអនុវត្តជាក់លាក់មួយចំនួនក្នុងការសួរដេញដោលទៅលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាពិសេសទៅលើ៖ ១/ ការអនុវត្តនៅក្នុងការអនុញ្ញាតឱ្យសាក្សីអានកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ខ្លួនជាមុន មុននឹងមកផ្តល់សក្ខីកម្ម និងបន្ទាប់មកឆ្លើយតបទៅនឹងសំណួរដោយផ្អែកលើឯកសារកំណត់ហេតុនៃការស្តាប់ចម្លើយទាំងនោះ។ ២/ ការកម្រិតដែលហួសហេតុពេកចំពោះវិសាលភាពនៃការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី។ ៣/ ការជឿទុកចិត្តហួសហេតុ

ពេកទៅលើសក្តីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំរបស់មេធាវីការពារក្តី នួនជា ដោយសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនឹងចេញនៅពេលក្រោយ។

## កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង

| លេខ E3 | លេខ កសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|
| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1398 | | 00065933-00066015<br>00814500-00814568<br>00823066-00823119 | Geography Text book of DK's Ministry of Education | P | 00065933 | 00814500 | 00823066 |
| E3/775 | | 00407096-00407108<br>00417940-00417947<br>00593926-00593935 | Global Vision: Revolution and non-revolution toward family building issue | P | 00407096-00407108 | 00417940-00417947 | 00593926-00593935 |
| E3/5832 | | 00402462-00402469<br>00410261-00410267<br>00434531-00434538 | Written Record of Interview of CHEANG Sreimom | P | 00402467 | 00410265 | 00434536 |
| E3/5837 | D25/24 | 00163455-00163464<br>00223450-00223458<br>00178089-00178096 | Written Record of Interview of KEV Chandara | P | 00163457<br>00163458<br>00163459<br>00163460<br>00163461<br>00163462<br>00163465 | 00223452<br>00223453<br>00223455<br>00223456<br>00223457 | 00178091<br>00178092<br>00178093<br>00178094<br>00178095 |
| E3/5153 | | 00172042-00172045<br>00205087-00205091<br>00205092-00205096 | Written Record of Interview of KEV Chandara | P | 00172043<br>00172044<br>00172045 | 00205088<br>00205090<br>00205091<br>00204089 | 00205093<br>00205094<br>00205095<br>00205096 |
| E3/2062 | | 00079436-00079442 | Brief history of "Genocidal Site" Kraing Ta Chan of Pol Pot-Ieng Sary Clique, Kus | P | 00079436 | 00301363 | 00789274 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00301363-00301370 00789274-00789282 | sub-district, Tram Kak district, Takeo province | | | | |
| E319.1.5 | | 00891165-00891168 00970441-00970445 00967221-00967225 | Written Record of Interview of KEV Chandara | SC | 00891168 | 00970445 | 00967225 |
| E3/5838 | D175/8.90 | 00032891-00032894 00713113-00713115 00710238-00710239 | Genocidal Report of Pol Pot in Tram Kak District | P | 00032891-00032894 | 00713113-00713115 | 00710238-00710239 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះ បដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលស្នើឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញ ពីការអនុវត្តជាក់លាក់មួយចំនួនក្នុងការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។

<u>កាលវេលាសវនាការបន្ត</u>

សវនាការនឹងបន្តទៅថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ០[illegible] ឆ្នាំ ២០១៥

ក្រឡាបញ្ជី [illegible] ក្រឡាបញ្ជី

**សែ គុលធុឡា** [illegible] **[illegible]ddalena GHEZZI**